**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃគញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៥០)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៤ ២៥៦ នាក់ នៃរោងចក្រ សហគ្រាស ទាំង៣៤ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃគញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ៦០ ៧៥០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៣៤ នេះ មិនបានទទួលសារទូរសព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមប្រញាប់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០២១

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

### ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១

### បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ៣៤ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 9 |
| 1 | ក្រុមហ៊ុន ស៊ីនហ្សុងយីង អ៊ឹមប្រយឌើរី & ថេកស្ទាយ ឯ.ក | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ជា ស៊ីណាត ហ្គាមេន ខូ អិលធីឌី | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ស៊ីនចាង ថេក អ៊ីន | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ហុង វ៉ា (កម្ពុជា) ហ្គាមិន ម៉ាញូហ្វាក់ធឺរីង លីមីធីត | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ហ៊ី លី តូ នីតធីង ខូ អិលធីឌី | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ហ្វ្រេន ថេកស្ទាយ(ខេមបូឌា)ខូអិលធីឌី | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ជីនវីន អ៊ីនដាសស្ទ្រី ខេមបូឌា ខូអិលធីឌី | កណ្តាល |
| 8 | ក្រុមហ៊ុន វីននីងជ្រាហ្គនឡេតធឺវែរ(ខេមបូឌា) ខូអិលធីឌី | កំពង់ស្ពឺ |
| 9 | ក្រុមហ៊ុន ហ៊ែលសា សៅ អិស អេស៊ា ខូ អិលធីឌី | ស្វាយរៀង |
| ខ. វិស័យទេសចរណ៍ | | 25 |
| 10 | ក្រុមហ៊ុន អូរៀនថល មីង រូម | ភ្នំពេញ |
| 11 | សណ្ឋាគារ រ៉េស៊ីដង់ សុខាភ្នំពេញ | ភ្នំពេញ |
| 12 | ក្រុមហ៊ុន អលទ្រីម (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 13 | ក្រុមហ៊ុន វីត្រូ អ៊ិនវេសមេន | សៀមរាប |
| 14 | ក្រុមហ៊ុន កូបេ យែកែននីស វែស្ទូវែន | សៀមរាប |
| 15 | សណ្ឋាគារ អង្គរប៉ារ៉ាឌី | សៀមរាប |
| 16 | សណ្ឋាគារ តារា អង្គរ | សៀមរាប |

| ល.រ | ឈ្មោះពេទចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 17 | ក្រុមហ៊ុន ជាតិថាតា អង្គរ | សៀមរាប |
| 18 | សណ្ឋាគារ វិរតន៍ | សៀមរាប |
| 19 | ភោជនីយដ្ឋាន វិរតន៍ | សៀមរាប |
| 20 | ក្រុមហ៊ុន វិរតន៍ វីឡា | សៀមរាប |
| 21 | សណ្ឋាគារប៉ារ៉ាឌីសអង្គរវីឡា | សៀមរាប |
| 22 | សណ្ឋាគារ លីនាយាអង្គរ រីសត និងស្ប៉ា | សៀមរាប |
| 23 | ក្រុមហ៊ុន ហ្គោលដេន ទ្រី ព្រីនស៍ ហូថេល និងស្ប៉ា | សៀមរាប |
| 24 | ក្រុមហ៊ុន រ៉ូយ៉ាល់អង្គរ (សណ្ឋាគារសូហ្វីតែលអង្គរភូគីត្រាហ្គោហ្វ & ស្ប៉ារីហ្សត) | សៀមរាប |
| 25 | ក្រុមហ៊ុន មុទិតា រីសត & ស្ប៉ា | សៀមរាប |
| 26 | ក្រុមហ៊ុន ដំរីអង្គរ ខូ អិលធីឌី | សៀមរាប |
| 27 | សណ្ឋាគារ យឹងដុម អង្គរ | សៀមរាប |
| 28 | ក្រុមហ៊ុន រុក្ខៈ រីវើរ រីសត | សៀមរាប |
| 29 | សណ្ឋាគារ ម៉ាល់ បេរី បូទិច អូតែល | សៀមរាប |
| 30 | ក្រុមហ៊ុន ឡូទុស ប្លង្គ រីសត | សៀមរាប |
| 31 | ក្រុមហ៊ុន អង្គរតែលេសរីហ្សត និងស្ប៉ា | សៀមរាប |
| 32 | ក្រុមហ៊ុន អ៊ីបេន ទ្រី ហាត់ | សៀមរាប |
| 33 | សណ្ឋាគារប៉ាស៊ីហ្វិក | សៀមរាប |
| 34 | សណ្ឋាគារស្ទឹងសៀមរាបថ្មី | សៀមរាប |